**The Royal Women’s Hospital** Women’s Health Information

# Endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) - ពត៌មានសំរាប់ស្ត្រី

*ខែមីនា ឆ្នាំ 2004*

## តើ endometriosis ជាអ្វីទៅ?

Endometriosis គឺជាស្ថានភាពទូទៅមួយ ដែលប៉ះពាល់ដល់ស្ត្រីប្រហែលដប់ភាគរយ។

ជំងឺនេះគឺជាស្ថានភាពមួយដែលគេរកឃើញថា ជាលិកា ធម្មតាគឺជាស្រទាប់ក្នុងរបស់ស្បូន ស្ថិតនៅតាមកន្លែងមិនធម្មតា នៅក្នុងរាងកាយ។ យ៉ាងណាមិញ គេរកឃើញ endometriosis នេះ នៅក្នុងម្ដុំសាច់ដុំឆ្អឹងត្រគាកយ៉ាងញឹកញាប់ណាស់។ ស្ថានភាពនេះ អាចបណ្ដាលឲ្យមានរោគសញ្ញាមួយចំនួន ដូចជាការឈឺចាប់នៅម្ដុំសាច់ដុំឆ្អឹងត្រគាក និង ការមិនអាចមានផ្ទៃពោះជាដើម។

## តើវាបណ្ដាលដោយមូលហេតុអ្វីទៅ?

គេនៅតែមិនទាន់ដឹងមូលហេតុពិតប្រាកដនៃ endometriosis ឡើយ។ ទ្រឹស្ដីមានប្រជាប្រិយបំផុតគឺថា ក្នុងអំឡុងពេលមានរដូវ ជាលិកានៃរដូវធ្វើដំណើរទៅក្រោយវិញ ដោយឆ្លងកាត់ដៃស្បូនចូលទៅក្នុងម្ដុំសាច់ដុំឆ្អឹងត្រគាក ហើយភ្ជាប់ខ្លួនវានិងដុះលូតលាស់នៅទីនោះ។

Endometriosis ទំនងជាជំងឺតពូជ ដូច្នេះអ្នកនឹងទំនងជាកើតជំងឺនេះ បើម្ដាយអ្នក ឬ ស្ត្រីមួយទៀតនៅក្នុងគ្រួសារអ្នក កើតមានជំងឺនេះ។

## តើគេធ្វើរោគវិនិច្ឆ័យរកឃើញវា តាមរបៀបណា?

វេជ្ជបណ្ឌិតនឹងពិភាក្សាជាមួយអ្នកអំពីរោគសញ្ញារបស់អ្នក ហើយក៏នឹងធ្វើការពិនិត្យរាងកាយផងដែរ។ អំពើនេះនឹងផ្ដល់ឲ្យវេជ្ជបណ្ឌិតនូវពត៌មានគ្រប់គ្រាន់ ដើម្បីសង្ស័យថា អ្នកមាន endometriosis ។

បើស្ត្រីម្នាក់មាន endometriosis នៅក្នុងអូវែររបស់ខ្លួន នោះវិធី ultrasound (សម្លេងអ៊ុលត្រា) អាចបង្ហាញវត្តមានរបស់វា ប៉ុន្តែមិនមែនជានិច្ចជាកាលនោះទេ។ គេអាចធ្វើរោគវិនិច្ឆ័យជាក់ច្បាស់ តែនៅក្នុងករណីដែលអ្នកឆ្លងកាត់ **វិធីវះឆ្លុះមើលក្នុងសំបុកពោះ (laparoscopy)** ឬ ការវះកាត់បើកមើលតែប៉ុណ្ណោះ។

**<u>វិធីវះឆ្លុះមើលក្នុងសំបុកពោះ</u>** គឺជាទំរង់ការមួយដែលគេបញ្ចូលកែវយឺតតូចឆ្មារមួយ ឆ្លងកាត់ការវះតូចមួយនៅនឹងពោះរបស់អ្នក។ ដើម្បីទទួលពត៌មានបន្ថែមអំពីវិធីវះឆ្លុះមើលក្នុងសំបុកពោះ សូមអានប័ណ្ណពត៌មាន ***ការព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង) ដោយប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ។***

វិធីវះឆ្លុះមើលក្នុងសំបុកពោះ មានប្រយោជន៍សំរាប់ការធ្វើរោគវិនិច្ឆ័យ ហើយក៏ជួយបង្ហាញភាពធ្ងន់ធ្ងរនៃ endometriosis ដែរ។ វិធីនេះក៏នឹងជួយវេជ្ជបណ្ឌិតធ្វើផែនការព្យាបាលល្អបំផុតសំរាប់អ្នកផងដែរ។

តេស្តរោគសាស្ត្រ ឬ “កាត់សាច់បន្តិចដើម្បីវិភាគមើល” (biopsy) នឹងធ្វើឡើងដើម្បីបញ្ជាក់នូវរោគវិនិច្ឆ័យនេះ។ អំពើនេះមានសារសំខាន់ ដោយសារតែជួនកាលទៅ គេអាចមានការភាន់ច្រឡំ endometriosis ជាមួយនឹងស្ថានភាពឯទៀត។

នៅគ្រាសព្វថ្ងៃ ប្រទេសអូស្ត្រាលីគ្មានតេស្តដែលពុំមានការវះកាត់ សំរាប់ការរកមើល endometriosis ឡើយ។

## តើវាអាចបណ្តាលឲ្យមានបញ្ហាឬទេ?

ស្ត្រីជាច្រើនមាន endometriosis ដោយគ្មានរោគសញ្ញា ឬ បញ្ហាទេ ប៉ុន្តែវាមិនតែងតែយ៉ាងដូច្នេះឡើយ។ រោគសញ្ញាធម្មតានៃ endometriosis មានរួមទាំង :

- ➢ ការឈឺចាប់នៅពេលមានរដូវ
- ➢ ការឈឺចាប់នៅពេលរួមរ័ក
- ➢ ការឈឺចាប់នៅត្រង់ម្តុំសាច់ដុំឆ្អឹងត្រគាក នៅគ្រាផ្សេងទៀតនៃដំណើរចុះឡើងនៃការមានរដូវ
- ➢ ឈឺចង្កេះ
- ➢ ថាមពលតិច
- ➢ ការឈឺចាប់ នៅពេលបន្ទោរបង់លាមក។

រោគសញ្ញាទាំងអស់នេះ អាចមានមូលហេតុផ្សេងទៀតដែរ។

ស្ត្រីខ្លះដែលលំបាកមានផ្ទៃពោះ ត្រូវបានរកឃើញថាមាន endometriosis ទោះជាអ្នកទាំងនោះគ្មានរោគសញ្ញាឯទៀតក៏ដោយ។

## តើ **endometriosis** មានផលប៉ះពាល់ដល់ភាពអាចមានផ្ទៃពោះ តាមវិធីណាដែរ?

មូលហេតុនៃការមិនអាចមានផ្ទៃពោះ គឺមានច្រើន ហើយចំពោះគូស្រករវិញ វាអាចមានមូលហេតុច្រើនជាងមួយ។ គេអាចរកឃើញ endometriosis នៅក្នុងស្ត្រីដែលកំពុងលំបាកនឹងមានផ្ទៃពោះ។ នៅក្នុងចំណោមស្ត្រីទាំងនេះ មួយចំនួនតូច ជាលិកាមានស្លាកស្នាមដោយសារ endometriosis នឹងបណ្តាលឲ្យរាំងស្ទះដល់ដៃស្បូន។

យ៉ាងណាមិញ ចំពោះស្ត្រីភាគច្រើនវិញ គេមិនដឹងច្បាស់ឡើយនូវមូលហេតុដែល endometriosis ប៉ះពាល់ដល់ភាពអាចមានផ្ទៃពោះរបស់ស្ត្រីទាំងនោះ។ ទ្រឹស្តីនានា មានរួមទាំងទ្រឹស្តីថា endometriosis:

- ប្រហែលជាធ្វើឲ្យពងមេជីវិតស្ត្រី មិនអាចបង្កាត់ជាមួយមេជីវិតបុរស ដើម្បីមានផ្ទៃពោះបានឡើយ
- បង្កើតជាតិពុលធម្មជាតិ ដល់មេទឹកកាមរបស់បុរស។

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women’s Health Information Centre (RWH)**
(03) 9344 2007
1800 442 007 (ទូរស័ព្ទឥតគិតថ្លៃ) អ៊ីមែល : whic@rwh.org.au
http://wellwomens.rwh.org.au

**Endometriosis Association of Victoria**
567 Waterdale Road
Heidelberg West
Victoria 3081
Australia
(03) 9457 2933
http://www.endometriosis.org.au/

**Gynaecology Clinic (គ្លីនិកជំងឺស្ត្រី) នៅ Royal Women’s Hospital**

គ្លីនិកនេះ មានទីតាំងនៅក្នុងអគារ outpatients (អ្នកជំងឺនៅក្រៅមន្ទីរពេទ្យ) នៅនឹងជាន់ក្រោមនៃ Royal Women’s Hospital
ទូរស័ព្ទ 9344 2183

## ប័ណ្ណពត៌មានឯទៀតរបស់ RWH ដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានប័ណ្ណពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត។ បើអ្នកចង់បានពត៌មានបន្ថែម អ្នកអាចបើកមើលវិបសៃផ្សព្វផ្សាយសុខភាពរបស់យើង។ អាសយដ្ឋានគឺ http://wellwomens.rwh.org.au

អ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ Royal Women’s Hospital ផ្ដល់ប័ណ្ណពត៌មានផងដែរ។ សុំយក :

- *ការព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)*
- *ការព្យាបាល endometriosis (ជំងឺស្រទាប់ក្នុងរបស់ស្បូននៅខុសកន្លែង)ដោយប្រើវិធីវះឆ្លុះមើលក្នុងសំបុកពោះ*